**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ..........សហវ.

**ក្រសួងទេសចរណ៍**

# ប្រកាសរួម

## ស្តីពី

## ការអនុញ្ញាតឱ្យជនបរទេសស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលប្រកបរបរវិជ្ជាជីវៈ ក្នុងវិស័យទេសចរណ៍និញ្ញប័ណ្ណចូលរមណីយដ្ឋានអង្គររយៈពេលវែង

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី**
**ក្រសួងទេសចរណ៍**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍



ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
#92, Sangkat Wat Phnom, Khan Doun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពារតំបន់រមណីយដ្ឋាននិងរៀបចំតំបន់អង្គរ កែសម្រួលដោយព្រះរាជក្រឹត្យលេខនស/រកត/០១៩៩/១៨ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩
- បានឃើញអនុក្រឹត្យលេខ១១អនក្រ.បកចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតគ្រឹះស្ថានអង្គរជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងស្មារតីអង្គប្រជុំក្រុមប្រឹក្សាភិបាលគ្រឹះស្ថានអង្គរអាណត្តិទី១លើកទី៥ នៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៧

## សម្រេច

**ប្រការ១.-**

ត្រូវបានអនុញ្ញាតឱ្យជនបរទេសស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលប្រកបបរវិជ្ជាជីវៈក្នុងវិស័យទេសចរណ៍ទិញប័ណ្ណចូលរមណីយដ្ឋានអង្គររយៈពេលវែងដែលមានលក្ខខណ្ឌដូចខាងក្រោម÷

-ជាបុគ្គលិករបស់ក្រុមហ៊ុនបានចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា

-បានចុះបញ្ជីពន្ធត្រឹមត្រូវនៅអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-មានអាជ្ញាប័ណ្ណអនុញ្ញាតប្រកបអាជីវកម្មពីក្រសួងទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា

-បុគ្គលិកដែលមានប័ណ្ណការងាររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២.-**

ក្រុមហ៊ុនដែលប្រកបអាជីវកម្មវិស័យទេសចរណ៍ និងបំពេញបានតាមលក្ខខណ្ឌដូចបានកំណត់នៅក្នុងប្រការ១ នៃប្រកាសរួមនេះ ទើបអនុញ្ញាតឱ្យគ្រឹះស្ថានអង្គរលក់ប័ណ្ណចូលរមណីយដ្ឋានអង្គររយៈពេលវែងជូនតាមសំណើ។

ការដាក់ពាក្យស្នើសុំទិញប័ណ្ណចូលរមណីយដ្ឋានអង្គររយៈពេលវែងទៅគ្រឹះស្ថានអង្គរ ត្រូវធ្វើឡើងតាមរយៈក្រុមហ៊ុនដែលប្រកបអាជីវកម្មវិស័យទេសចរណ៍ និងបំពេញបានតាមលក្ខខណ្ឌដូចបានកំណត់នៅក្នុងប្រការ១ ខាងលើ ។

**ប្រការ៣.-**

ប័ណ្ណចូលរមណីយដ្ឋានអង្គររយៈពេលវែងមានចំនួនបីប្រភេទដូចខាងក្រោម÷

-ប័ណ្ណមានសុពលភាពរយៈពេល ១ (មួយ) ខែគឺមានតម្លៃ ១០០ (មួយរយ) ដុល្លារ

-ប័ណ្ណមានសុពលភាពរយៈពេល៣ (បី) ខែ គឺមានតម្លៃ ១៥០ (មួយរយហាសិប) ដុល្លារ

-ប័ណ្ណមានសុពលភាពរយៈពេល៦ (ប្រាំមួយ) ខែគឺមានតម្លៃ ២០០ (ពីររយ) ដុល្លារ។

**ប្រការ៤.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងទេសចរណ៍ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរជាតិអប្សរា គ្រឹះស្ថានអង្គរ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែ[illegible] ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងទេសចរណ៍**

**ថោង ខុន**

**កន្លែងទទួល:-**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងទេសចរណ៍
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ